# ភ្លេងជាតិ នគររាជ

១- សូមពួកទេព្តា រក្សា មហាក្សត្រយើង
ឱ្យ បានរុងរឿង ដោយជ័យមង្គល សិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន ។

២- ប្រាសាទសិលា កំបាំងកណ្តាលព្រៃ
គួរឱ្យស្រម័យ នឹកដល់យសស័ក្តិ មហានគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ។

៣- គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌
សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឱ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ។

ចម្លងចេញពីសៀវភៅ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ដោយខ្ញុំបាទ វ៉ាត់ អ៊ុង ព.ស. ២៥៥៤

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ អ៊ិន លី ថ្ងៃទី១៧ ខែតុលា គ.ស.២០១២

